## សាលាសាធារណៈក្រុងលីន

## មណ្ឌលពត៌មានមាតាបិតា

# ដំណើរការប្តឹងតវ៉ា

# ការបញ្ជូនសិស្ស


**ការិយាល័យរដ្ឋបាល**

**100 Bennett Street, 1St Floor**
**Lynn, MA 01905**

**ទូរស័ព្ទ: (781) 592-8796**

**ហ្វាក់: (781) 598-3160**

# **ដំណើរការប្តឹងតវ៉ា**

ច្បាប់បញ្ជូនសិស្ស

ផ្អែកតាមគម្រោងស្មគ្រ័ចិត្តសាលាសាធារណៈក្រុងលីន សម្រាប់ការកែលំអ និងការលប់បំបាត់ចោល នៃភាពឯកកោភាគតិច ដែលបានអនុញ្ញាតិដោយ គណៈកម្មការសាលាសាធារណៈក្រុងលីន និងក្រុមប្រឹក្សាអប់រំរដ្ឋម៉ាស្សាជូស្សិត **សិស្សទាំងអស់ត្រូវចូលរៀននៅសាលាភូមិភាគរបស់ពួកគេបាន**។ សំណើសម្រាប់ការដកចេញពីភូមិភាគ ត្រូវបានកំណត់ដោយការរើសអើងពូជសាសន៍ និងទំហំថ្នាក់នៃសាលាក្រៅភូមិភាគ។

ការដាក់ចេញក្រៅភូមិភាគមិនត្រូវបានធានានោះទេ។ សិស្សភូមិភាគ អាចមិនមានកន្លែង ដកចេញដាក់ក្រៅភូមិភាគបាន បើទំហំថ្នាក់ឈានដល់គ្រប់ចំណុះកៅអី (សិស្ស 30នាក់)។ បើមិនមានកន្លែង សិស្សក្រៅភូមិភាគ នឹងត្រូវតម្រូវអោយផ្លាស់ទៅសាលាភូមិភាគរបស់ពួកគេ ឬទៅសាលាផ្សេងតាមជម្រើស។

ក្នុងករណីខ្លះ ការផ្លាស់ប្តូរសាលាដែលស្នើសុំដោយមាតាបិតាសិស្ស មិនមានជម្រើសនៅក្នុងក្បួនណែនាំទេ។ បើមាតាបិតាចង់បដិសេធការដាក់ទៅសាលាណាមួយ ដែលជាជម្រើស គាត់មានសិទ្ធិប្តឹងការដាក់បញ្ជូន/ការបញ្ជូន សម្រាប់មូលហេតុដូចខាងក្រោម:

**សុខភាព**

- ខ្វះនើសនៅកន្លែងពេញម៉ោង
- អាគារអាចចេញចូលជាទូទៅ

*ឯកសារដែលតម្រូវ:*

សំបុត្រពេទ្យ និង/ឬឯកសារផ្លូវការពីសាលាមុន

**សុវត្ថិភាព**

- ជនរងគ្រោះដោយការរំលោភបំពានយ៉ាងខ្លាំង និង/ឬជាទំលាប់
- វាយដំ និងរំលោភបំពាន
- ការគំរាមកំហែងដែលពាក់ព័ន្ធក្រុមហ្គេង (ជនពាល)

*ឯកសារដែលតម្រូវ:*

របាយការណ៍ប៉ូលីស និងឯកសារសាលាជាផ្លូវការ (នាយក បុគ្គលិកខាងវត្តមាន និង/ឬអ្នកប្រឹក្សាណែនាំ)

**ផ្លាស់ប្តូរក្នុងលក្ខខ័ណ្ឌពូជសាសន៍**

- ផ្លាស់ប្តូរនៃលក្ខខ័ណ្ឌពូជសាសន៍ដោយសារកំហុសក្នុងទិន្នន័យសិស្ស
- យល់ច្រឡំនៃលក្ខខ័ណ្ឌពូជសាសន៍នៅពេលចុះឈ្មោះ

*ឯកសារដែលត្រូវ:*

ទម្រង់បែបបទការស្ទង់ជាតិសាសន៍ ជាមួយនឹងលក្ខខ័ណ្ឌជាតិសាសន៍ថ្មី និង/ឬដែលជាប់ទាក់ទងជាមួយកុលសម្ព័ន្ធ ឬការដាក់ភ្ជាប់មកជាមួយនូវទម្រង់បែបបទសហគមន៍

**បងប្អូនបង្កើត**

- បងប្អូនបង្កើតរបស់សិស្សដែលចូលរៀនសាលាក្រៅភូមិភាគ

ករណីទាំងនេះ ត្រូវអនុវត្តតាមក្បួនណែនាំនៃច្បាប់បញ្ជូនសិស្ស តាមគម្រោងការស្មគ្រ័ចិត្តសម្រាប់ការកែលំអ និងការលប់បំបាត់ចោល នៃភាពឯកកោភាគតិច។

*ឯកសារដែលត្រូវ:*

ទម្រង់បែបបទប្តឹងដែលមានដាក់ឈ្មោះ និងលេខអាយឌីសិស្សនៃបងប្អូនដែលរៀននៅសាលាក្រៅភូមិភាគ

បណ្តឹងដែលបានដាក់បញ្ជូនមកសម្រាប់មូលហេតុនេះ ត្រូវបានអនុញ្ញាតិអោយនៅពេលចុះឈ្មោះ និង/ឬពេលដំណើរការបញ្ជូនសិស្ស បើទំហំថ្នាក់នៅមាន មិនដូច្នេះទេ គេនឹងត្រូវបានដាក់ទៅតារាងបញ្ជីរង់ចាំ។

**ដំណើរការប្តឹងត្រូវបានចាត់ចែងដោយបុគ្គលិកមណ្ឌលពត៌មានមាតាបិតា។ ក្នុងអំឡុងឆ្នាំសិក្សា មាតាបិតា/អ្នកអាណាព្យាបាលត្រូវបានជូនដំណឹងនៃការសម្រេចចិត្តចំពោះបណ្តឹង តាមរយៈ មណ្ឌលពត៌មានមាតាបិតា ក្នុងរយៈពេលកំណត់១សប្តាហ៍។**